**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣០០ ព.ណ-ចបព-ប្រក

ភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៨

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចាំបាច់ក្នុងទិសដៅកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ។
-បានឃើញប្រកាសលេខ ២៩៩ ពណ.ចបព.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

# <u>សម្រេច</u>

**<u>ប្រការ១៖</u>**

កំណត់ឲ្យរាល់ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុគ្គលសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយ ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ មកចុះបញ្ជីសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មតាមគេហទំព័រ:www.businessregistration.moc.gov.kh ដើម្បីឲ្យការផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យ ការបំពេញទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវផ្ញើជូន ឬចេញដោយក្រសួងពាណិជ្ជកម្មអាចធ្វើទៅបានតាមប្រព័ន្ធអេឡិចត្រូនិក។

**<u>ប្រការ២៖</u>**

អភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាស ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវ។ អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសដែលបានចុះបញ្ជីសាឡើងវិញរួចហើយនឹងទទួលបានលេខចុះបញ្ជី និងវិញ្ញាបនបត្រថ្មីដែលផ្តល់ឲ្យតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយពុំមានកំណត់សុពលភាព ។

**<u>ប្រការ៣៖</u>**

ការចុះបញ្ជីសាឡើងវិញដូចមានចែងក្នុងប្រការ១ ត្រូវធ្វើឡើងចាប់ពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងអស់មិនទាន់បានចុះបញ្ជីសាឡើងវិញ ក្នុងចន្លោះពេលពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ត្រូវតែបម្រុងទុកនាមករណ៍ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីចៀសវាងការបាត់បង់ឈ្មោះដែលបានចុះបញ្ជីមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦។ នាមករណ៍បម្រុងទុកមានសុពលភាព០៣ (បី) ខែ និងអាចស្នើសុំពន្យារពេល០៣ (បី)ខែ បន្តទៀតបាន ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ការបម្រុងទុកនាមករណ៍តាមប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចមុន ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ត្រូវបញ្ចូលឯកសារវិញ្ញាបនប័ត្រដែលបានចុះបញ្ជី។

ក្នុងករណីអភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាសមិនអាចបំពេញព័ត៌មាន និងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវដោយខ្លួនឯងបាន អាចអញ្ជើញមកក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មជួយបំពេញព័ត៌មាន និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស។

**ប្រការ៤៖**

ក្នុងករណី អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាស មិនបានចុះបញ្ជីសាឡើងវិញតាមកាលបរិច្ឆេទកំណត់ក្នុងប្រការ៣ នោះការចុះបញ្ជីសាឡើងវិញនៅតែអាចធ្វើបន្តបានរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ តែត្រូវបង់កម្រៃសេវាសាធារណៈពេញលេញដូចជាការចុះបញ្ជីថ្មីដែរ។

**ប្រការ៥៖**

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងឡាយមិនបានចុះបញ្ជីសាឡើងវិញមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ទេនោះ ក្រសួងពាណិជ្ជកម្មនឹងធ្វើលិខិតបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជម្រះកាតព្វកិច្ចពន្ធដារ និងបញ្ជូនទៅតុលាការដើម្បីអនុវត្តតាមនីតិវិធីច្បាប់។

**ការ៦៖**

ការទូទាត់កម្រៃសេវាដែលត្រូវបង់ចូលជាថវិកាជាតិ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារផ្ទេរតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៨៣ សហវ. ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។ ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ។ ក្នុងករណី ស្ថាបនិក ឬអភិបាល ឬម្ចាស់ហ៊ុនអញ្ជើញមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ការទូទាត់កម្រៃសេវាត្រូវធ្វើដោយផ្ទាល់នៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៧៖**

ខ្លឹមសារប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៨៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ **គាត ឈន់**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា **"ដើម្បីជូនជ្រាប"**
- ដូចប្រការ៨ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ